## ធនាគារ ព្រីនស៍ ម.ក

## បញ្ញត្តិ និងលក្ខខណ្ឌសម្រាប់កម្មវិធីលើកទឹកចិត្តប្រើប្រាស់ប័ណ្ណ MASTERCARD ជាមួយស្ថានីយ៍ប្រេងឥន្ធនៈកាល់តិច

ធនាគារ ព្រីនស៍ ម.ក ("**ធនាគារ ព្រីនស៍**") កំពុងដាក់ដំណើរការកម្មវិធីលើកទឹកចិត្តប្រើប្រាស់ប័ណ្ណ MasterCard ជាមួយស្ថានីយ៍ប្រេងឥន្ធនៈកាល់តិច ដោយអនុលោមតាមបញ្ញត្តិ និងលក្ខខណ្ឌ ដែលបានចែងនៅទីនេះ ("**កម្មវិធីលើកទឹកចិត្ត**")។ តាមរយៈការចូលរួមកម្មវិធីលើកទឹកចិត្តនេះ អតិថិជន យល់ព្រមអនុវត្តតាមបញ្ញត្តិ និងលក្ខខណ្ឌដូចខាងក្រោម ព្រមទាំងបញ្ញត្តិ និងលក្ខខណ្ឌទូទៅ បញ្ញត្តិ និងលក្ខខណ្ឌនៃការប្រើប្រាស់ប័ណ្ណឥណទាន បញ្ញត្តិ និងលក្ខខណ្ឌនៃការប្រើប្រាស់ប័ណ្ណ និងបញ្ញត្តិ និងលក្ខខណ្ឌដែលពាក់ព័ន្ធដទៃទៀតៈ

១. រាល់ អតិថិជនជារូបវន្តបុគ្គលដែលកំពុងប្រើប្រាស់ប័ណ្ណឥណពន្ធ ឬប័ណ្ណឥណទាន MasterCard (ប្រភេទ Standard ឬ Platinum) ចេញជូនដោយ ធនាគារ ព្រីនស៍ ("**អ្នកចូលរួម**") អាចចូលរួមកម្មវិធីលើកទឹកចិត្តនេះ។

២. អតិថិជនដែលបានបំពេញលក្ខខណ្ឌដូចខាងក្រោម នឹងទទួលបាននូវរង្វាន់លើកទឹកចិត្ត ("**រង្វាន់លើកទឹកចិត្ត**") ស្របតាមបញ្ញត្តិ និងលក្ខខណ្ឌខាងក្រោម។

| **ប្រភេទប្រតិបត្តិការ** | **ពាណិជ្ជករ** | **រង្វាន់លើកទឹកចិត្ត (សាច់ប្រាក់ត្រឡប់វិញ)** | | **រយៈពេលកម្មវិធីលើកទឹកចិត្ត** |
|---|---|---|---|---|
| | | **ប្រភេទ Standard** | **ប្រភេទ Platinum** | |
| រាល់ប្រតិបត្តិការទិញ តាមម៉ាស៊ីនឆូតកាត ដោយប្រើប្រាស់ប័ណ្ណ MasterCard ធនាគារ ព្រីនស៍ (ទាំងប័ណ្ណឥណពន្ធ ឬប័ណ្ណឥណទាន) | ស្ថានីយ៍ប្រេងឥន្ធនៈកាល់តិច (ក្រុមហ៊ុន ឈេហ្វរ៉ុន (ខេមបូឌា) លីមីធីត) ដូចមានភ្ជាប់នៅឧបសម្ព័ន្ធ១ | ១៥% នៃវិក្កយបត្រ (កម្រិតត្រឹម ២៥$ ក្នុងមួយខែ និងអ្នកចូលរួមម្នាក់) | ២៥% នៃវិក្កយបត្រ (កម្រិតត្រឹម ៣៥$ ក្នុងមួយខែ និងអ្នកចូលរួមម្នាក់) | ០១ មីនា ដល់ ៣១ ឧសភា ២០២៥ |

(*សម្គាល់៖ រង្វាន់លើកទឹកចិត្តនឹងផ្តល់ជូនយ៉ាងយូរត្រឹមសប្តាហ៍ទី២ នៃខែបន្ទាប់នៃប្រតិបត្តិការ។ អ្នកចូលរួមម្នាក់ៗ ត្រូវកំណត់ដោយលេខសម្គាល់អតិថិជន (CIF)។)

៣. ដោយមិនមានតម្រូវឱ្យមានការទាមទារណាមួយពីអ្នកចូលរួម រង្វាន់លើកទឹកចិត្តក្នុងទម្រង់ជាការប្រគល់សាច់ប្រាក់ត្រឡប់វិញ នឹងត្រូវបានដាក់ចូលទៅក្នុងគណនីចរន្ត ឬគណនីសន្សំដែលភ្ជាប់ជាមួយនឹងប័ណ្ណឥណទាន ឬប័ណ្ណឥណពន្ធរបស់អ្នកចូលរួម ដែលត្រូវបានប្រើប្រាស់ដើម្បីធ្វើប្រតិបត្តិការបញ្ជាទិញ ដោយអនុលោមតាមបញ្ញត្តិ និងលក្ខខណ្ឌនេះ ដោយស្វ័យប្រវត្តិ។ សាច់ប្រាក់ដែលនឹងត្រូវទទួលត្រឡប់វិញ នឹងត្រូវបានផ្តល់ជូនអ្នកចូលរួម ដោយអនុលោមតាម បញ្ញត្តិ និងលក្ខខណ្ឌនេះ នៅក្នុងរយៈពេលកម្មវិធីលើកទឹកចិត្ត ឬរហូតដល់ពេលដែលគម្រោងថវិកាដែលត្រូវបានអនុម័តសម្រាប់កម្មវិធីលើកទឹកចិត្តនេះ ត្រូវបានចំណាយអស់។

៤. ប្រសិនបើគណនីចរន្ត ឬគណនីសន្សំដែលភ្ជាប់ជាមួយនឹងប័ណ្ណឥណទាន ឬប័ណ្ណឥណពន្ធ ត្រូវបានបិទមុនកាលបរិច្ឆេទនៃការប្រគល់សាច់ប្រាក់ត្រឡប់វិញ ដូចបានចែងនៅក្នុងបញ្ញត្តិនិងលក្ខខណ្ឌនេះ ហើយម្ចាស់ប័ណ្ណបានបញ្ចប់ទំនាក់ទំនងជាមួយ ធនាគារ ព្រីនស៍ (មិនបន្តប្រើប្រាស់ប័ណ្ណឥណទាន ឬប័ណ្ណឥណពន្ធ ប្រភេទណាមួយរបស់ MasterCard ដែលចេញដោយ ធនាគារ ព្រីនស៍) នោះម្ចាស់ប័ណ្ណនឹងមិនមានសិទ្ធិក្នុងការទទួលបាន ឬទាមទារយករង្វាន់លើកទឹកចិត្តដែលបានផ្តល់ជូន នៅក្រោមកម្មវិធីលើកទឹកចិត្តនេះឡើយ។

៥. ក្នុងករណីមានការឆបោក ឬក្លែងបន្លំដែលប្រព្រឹត្តដោយ ឬមានពាក់ព័ន្ធនឹងអ្នកចូលរួមទាក់ទងនឹងកម្មវិធីលើកទឹកចិត្តនេះ អ្នកចូលរួមរូបនោះនឹងបាត់បង់សិទ្ធិចូលរួមកម្មវិធីលើកទឹកចិត្តនេះ ដោយរួមទាំងអត្ថប្រយោជន៍ផ្សេងៗដែលខ្លួនទទួលបាន។ អ្នកចូលរួមត្រូវប្រគល់ជូនធនាគារ ព្រីនស៍ វិញ នូវរាល់អត្ថប្រយោជន៍ដែលខ្លួនបានទទួលពី ធនាគារ ព្រីនស៍ តាមរយៈកម្មវិធីលើកទឹកចិត្តនេះ (ប្រសិនបើមាន) និងត្រូវសងសំណងការខូចខាតផ្សេងៗទៅតាមបញ្ញត្តិច្បាប់ជាធរមាន។

៦. ការរក្សាសិទ្ធិ ការរួចផុត និងការកម្រិតនៃការទទួលខុសត្រូវ

   ក. អ្នកចូលរួម យល់ព្រមថា ធនាគារ ព្រីនស៍ រួមបញ្ចូលទាំង ម្ចាស់ភាគហ៊ុន អភិបាល ឬបុគ្គលិករបស់ ធនាគារ ព្រីនស៍ មិនត្រូវទទួលខុសត្រូវលើ រាល់ការខូចខាតណាមួយ ទោះដោយផ្ទាល់ ឬដោយប្រយោល ជាពិសេស ឬដោយចៃដន្យ ដែលកើតឡើង ទាក់ទងនឹងកម្មវិធីលើកទឹកចិត្តនេះឡើយ។

   ខ. អ្នកចូលរួម យល់ព្រមដោយមិនអាចដកហូតវិញបានថា អ្នកចូលរួមយល់ព្រមសងសំណង និងធានាថា ធនាគារ ព្រីនស៍ នឹងទទួលបានសំណងគ្រប់ពេលណាមួយ លើរាល់ការបាត់បង់ ការខូចខាត កម្រៃសេវា កម្រៃសេវាផ្លូវច្បាប់ និងការចំណាយផ្សេងៗ និងរាល់ផលវិបាកដែលកើតឡើងលើ ធនាគារ ព្រីនស៍ ឬបានទទួលរងដោយ ធនាគារ ព្រីនស៍ ចំពោះការទាមទារ ឬបណ្តឹងណាមួយដែលធ្វើឡើងដោយអ្នកចូលរួម ឬភាគីទីបី ដែលកើតឡើង ឬទាក់ទងនឹងបញ្ញត្តិដែលមានចែងក្នុងបញ្ញត្តិនិងលក្ខខណ្ឌនេះ។

   គ. ធនាគារ ព្រីនស៍ មិនទទួលខុសត្រូវ ទោះក្នុងទម្រង់ណាមួយ ចំពោះការខូចខាត ឬការខាតបង់ដែលកើតចេញពីប្រតិបត្តិការរវាងអ្នកចូលរួម និងស្ថានីយ៍ប្រេងឥន្ធនៈកាល់តិចឡើយ។

៧. ធនាគារ ព្រីនស៍ រក្សាសិទ្ធិគ្រប់យ៉ាង ក្នុងការធ្វើវិសោធនកម្មលើបញ្ញត្តិនិងលក្ខខណ្ឌនេះ ពន្យាពេល បន្ថែមរយៈពេល ឬលុបចោលកម្មវិធីលើកចិត្តនេះ និង/ឬរង្វាន់លើកទឹកចិត្ត នៅពេលណាមួយក្នុងរយៈពេលកម្មវិធីលើកទឹកចិត្ត ដោយមិនមានការទទួលខុសត្រូវ តាមឆន្ទានុសិទ្ធិដាច់ខាតរបស់ ធនាគារ ព្រីនស៍ ដោយគ្រាន់តែផ្តល់ការជូនដំណឹងពីការផ្លាស់ប្តូរ នៅលើគេហទំព័រផ្លូវការ ឬតាមមធ្យោបាយទំនាក់ទំនងផ្សេងទៀតរបស់ ធនាគារ ព្រីនស៍។

៨. បញ្ញត្តិនិងលក្ខខណ្ឌនេះ ត្រូវបានគ្រប់គ្រងដោយច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ រាល់វិវាទដែលកើតឡើង ឬទាក់ទងនឹងកម្មវិធីលើកទឹកចិត្តនេះ នឹងត្រូវបានដោះស្រាយ ដោយអនុលោមតាម

គោលនយោបាយដោះស្រាយបណ្តឹងអតិថិជនរបស់ធនាគារ និងតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

## ឧបសម្ព័ន្ធ១

## បញ្ជីស្ថានីយ៍ប្រេងឥន្ធនៈកាល់តិចទាំង៨៦ ដែលចូលរួម

| លរ | ឈ្មោះស្ថានីយ៍ | រាជធានី/ខេត្ត |
|---|---|---|
| ១ | CALTEX POCHENTONG | ភ្នំពេញ |
| ២ | CALTEX ROAD 6A | ភ្នំពេញ |
| ៣ | CALTEX APSARA | ភ្នំពេញ |
| ៤ | CALTEX BOKOR | ភ្នំពេញ |
| ៥ | CALTEX ROAD 5B | ភ្នំពេញ |
| ៦ | CALTEX CALMETTE | ភ្នំពេញ |
| ៧ | CALTEX MEKONG | ភ្នំពេញ |
| ៨ | CALTEX TOEUK LAORK | ភ្នំពេញ |
| ៩ | CALTEX CHAK ANGRE | ភ្នំពេញ |
| ១០ | CALTEX CHBAR AMPEAUV | ភ្នំពេញ |
| ១១ | CALTEX BOEUNG TRABEK | ភ្នំពេញ |
| ១២ | CALTEX PETLOKSANG | ភ្នំពេញ |
| ១៣ | CALTEX BEUNG KENG KANG | ភ្នំពេញ |
| ១៤ | CALTEX PSAR DEUMKOR | ភ្នំពេញ |
| ១៥ | CALTEX PSAR DEIHOY STATION | ភ្នំពេញ |
| ១៦ | CALTEX STOEUNG MEANCHEY STATION | ភ្នំពេញ |
| ១៧ | CALTEX SEN SOK STATION | ភ្នំពេញ |
| ១៨ | BAYONG MEANCHEY CO., LTD | ភ្នំពេញ |
| ១៩ | CALTEX ROAD 2004 STATION | ភ្នំពេញ |
| ២០ | CALTEX AEON 2 STATION | ភ្នំពេញ |
| ២១ | PHSAR DAEUM THKOV 271 PETROL STATION | ភ្នំពេញ |
| ២២ | CALTEX STREET 1986 STATION | ភ្នំពេញ |
| ២៣ | Caltex Toul Pungror station | ភ្នំពេញ |
| ២៤ | KRAING THNUNG PETROL STATION | ភ្នំពេញ |

| | | |
|---|---|---|
| ២៥ | Caltex Odem station | ភ្នំពេញ |
| ២៦ | Caltex TK Street 592 | ភ្នំពេញ |
| ២៧ | Caltex Chamkar Dong station | ភ្នំពេញ |
| ២៨ | Caltex Beung kok station | ភ្នំពេញ |
| ២៩ | RORO Chhouk Meas | ភ្នំពេញ |
| ៣០ | RORO Prey Sar Road | ភ្នំពេញ |
| ៣១ | RORO Tang Korsang | ភ្នំពេញ |
| ៣២ | RORO Road No 3 | ភ្នំពេញ |
| ៣៣ | RORO Road 598 | ភ្នំពេញ |
| ៣៤ | RORO Angkor Blvd | ភ្នំពេញ |
| ៣៥ | RORO Plaza | ភ្នំពេញ |
| ៣៦ | RORO Toul Kork Pen Nuth | ភ្នំពេញ |
| ៣៧ | RORO Caltex Prek Pnov | ភ្នំពេញ |
| ៣៨ | RORO Tiger Beer Road-Prek Eng | ភ្នំពេញ |
| ៣៩ | RORO Kob Srov Road | ភ្នំពេញ |
| ៤០ | RORO Toul Sang Kae | ភ្នំពេញ |
| ៤១ | RORO Toul Kei | ភ្នំពេញ |
| ៤២ | RORO Samroung Andet | ភ្នំពេញ |
| ៤៣ | RORO Prek Eng | ភ្នំពេញ |
| ៤៤ | CALTEX PREK TAMAK STATION | កណ្ដាល |
| ៤៥ | CALTEX TAKHMAO STATION | កណ្ដាល |
| ៤៦ | Caltex Angsnoul station (Old SOK CHAN SOPHEAR 8214097) | កណ្ដាល |
| ៤៧ | RORO Korkie Market | កណ្ដាល |
| ៤៨ | RORO Takhmao Road 21 | កណ្ដាល |
| ៤៩ | KM33 (Kandal Stueng) | កណ្ដាល |
| ៥០ | CALTEX SIHANOUKVILLE - 2 | ក្រុងព្រះសីហនុ |

| | | |
|---|---|---|
| ៥១ | CALTEX SIHANOUKVILLE - 1 (KLANG LEU) STATION | ក្រុងព្រះសីហនុ |
| ៥២ | RORO Mittapheap | ក្រុងព្រះសីហនុ |
| ៥៣ | RORO SHV 4 | ក្រុងព្រះសីហនុ |
| ៥៤ | RORO Veal Rinh | ក្រុងព្រះសីហនុ |
| ៥៥ | CALTEX KAMPONG CHAM | កំពង់ចាម |
| ៥៦ | CALTEX SKUN STATION | កំពង់ចាម |
| ៥៧ | RORO Tonle Om | កំពង់ចាម |
| ៥៨ | Caltex Kampong Thom station | កំពង់ធំ |
| ៥៩ | Caltex Kampong Speu station | កំពង់ស្ពឺ |
| ៦០ | RORO Pich Nil | កំពង់ស្ពឺ |
| ៦១ | CALTEX KAMPOT STATION | កំពត |
| ៦២ | RORO La Ang | កំពត |
| ៦៣ | CALTEX ANG TASOM STATION | តាកែវ |
| ៦៤ | CALTEX TAKEO STATION | តាកែវ |
| ៦៥ | RORO Ang Tasom Soksan | តាកែវ |
| ៦៦ | Caltex Suong station | ត្បូងឃ្មុំ |
| ៦៧ | RORO Krek | ត្បូងឃ្មុំ |
| ៦៨ | Caltex  Poi Pet station | បន្ទាយមានជ័យ |
| ៦៩ | Caltex Banteay Mean chey station | បន្ទាយមានជ័យ |
| ៧០ | CALTEX LOKTA DOMBANG KRONHONG | បាត់ដំបង |
| ៧១ | CALTEX BATTAMBANG THMEY station | បាត់ដំបង |
| ៧២ | RORO Battambong O Cha | បាត់ដំបង |
| ៧៣ | RORO Battambong Town | បាត់ដំបង |
| ៧៤ | RORO Krung Pursat | ពោធិសាត់ |
| ៧៥ | RORO Svay Antor | ព្រៃវែង |
| ៧៦ | RORO Mundol Kiri | មណ្ឌលគិរី |

| | | |
|---|---|---|
| ៧៧ | CALTEX ANGKOR | សៀមរាប |
| ៧៨ | CALTEX SIEM REAP (CHONG KAO SOU) STATION | សៀមរាប |
| ៧៩ | RORO 7 Makara | សៀមរាប |
| ៨០ | RORO Pouk Market | សៀមរាប |
| ៨១ | RORO Apollo Plaza | សៀមរាប |
| ៨២ | RORO Street 30 Siem Reap | សៀមរាប |
| ៨៣ | RORO Win Win | សៀមរាប |
| ៨៤ | RORO Vattanak | សៀមរាប |
| ៨៥ | Caltex KRONG BAVET 2 station | ស្វាយរៀង |
| ៨៦ | RORO Svay Rieng | ស្វាយរៀង |